# គ្រប់ការទាំងអស់ផ្សំគ្នាសំរាប់សេចក្តីល្អ

*អែលឌើរ ជេមស៍ ប៊ី ម៉ាទីណូ*
*នៃពួកកូរ៉ុមចិតសិបនាក់*

ពេលខ្ញុំនៅក្មេងខ្ញុំទន្ទឹងរង់ចាំរដូវផ្ការីកចូលមកដល់។ នៅពេលអាកាសធាតុកក់ក្តៅ នោះខ្ញុំបានត្រៀមខ្លួនជាស្រេច សំរាប់ការចាប់ផ្តើមកីឡា បេស្បូល ម្តងទៀត។ ដូចក្មេងប្រុសភាគច្រើនផងដែរ ខ្ញុំមានបំណងប្រាថ្នាថា ខ្ញុំនឹងក្លាយទៅជាកីឡាករ បេស្បូល ដ៏អស្ចារ្យម្នាក់។ ខ្ញុំសូមរំឭកឡើងវិញអំពីរឿងរបស់ក្មេងប្រុសម្នាក់ ដែលមាន ក្តីស្រមៃស្រដៀងគ្នានេះដែរ។ ជាមួយនឹងបំណងប្រាថ្នាចង់ក្លាយជាកីឡាករបាល់បោះដ៏អស្ចារ្យបន្ទាប់ គាត់បាន សម្រេចចិត្តថាត្រូវចេញទៅខាងក្រៅ ដើម្បីអនុវត្ត។ គាត់បាន កាន់ បេស្បូល នៅក្នុងដៃហើយចោលវាឡើងទៅលើ ព្រមជាមួយនឹងបំណងប្រាថ្នាថាគាត់នឹងវាយកូនបាល់ឱ្យបានឆ្ងាយបំផុតតាមដែលអាចធ្វើទៅបាន គាត់យកដំបងដ៏ធំ មួយក្រវី ប៉ុន្តែដំបងបានធ្លាក់ ទៅលើ ដីមិនទាំងប៉ះឈើដំបងផង។ ដោយគ្មានការប្រកែកអ្វីទាំងអស់ គាត់បានទៅធ្វើ ដូច្នេះម្តងទៀត។ គាត់រៀប នឹងគប់បាល់ទៅហើយ ការប្តេជ្ញាចិត្តរបស់គាត់បានកើនឡើង ជាគំនិតមួយដ៏មានអំណាចថា ត្រូវតែវាយ បានជ្រាបចូលក្នុងដួងចិត្តរបស់គាត់។ ប៉ុន្តែជាអកុសល លទ្ធផលនៅតែដូចមុន។ បាល់បានធ្លាក់ទៅលើដី។ ប៉ុន្តែដូចអ្នកលេង បេស្បូល ដ៏ល្អទាំងអស់បានដឹងស្រាប់ហើយថា អ្នកមានឱកាសបីដង មុនពេលដែលអ្នកត្រូវចេញ។ គាត់បានយកចិត្តទុកដាក់កាន់តែខ្លាំង នៅពេលគប់បាល់ទៅខាងលើ ហើយបានគ្រវី ដំបងយ៉ាងមានអំណាច គឺគាត់បាន ព្យាយាមកាន់តែខ្លាំងជាងមុន។ នៅពេលកូនបាល់ធ្លាក់ទៅលើដីម្តងទៀត គាត់បានហូរទឹកភ្នែក រំពេចនោះស្រាប់តែស្នាមញញឹមដ៏ធំមួយបានលេចឡើង ហើយគាត់ បានបាននិយាយថា «ឱ! អ្នកគប់អើយ»។

យើងទាំងអស់គ្នា នឹងប្រឈមមុខនឹងឧបសគ្គ ព្រមទាំងការសាកល្បង ដូចជានៅក្នុងឧទាហរណ៍ដ៏សាមញ្ញរបៀបដែលយើងមានប្រតិកម្មតបចំពោះការពិបាកទាំងនោះនឹងកំណត់អំពីជោគជ័យ និងសុភមង្គលរបស់យើង។ យើងម្នាក់ៗនឹងប្រឈមមុខនឹងមាសត្រូវ ទោះបីជាយើងនៅទីណាក្តី។ យើងត្រូវបានបង្រៀននៅក្នុងព្រះគម្ពីរថា៖ «ត្បិតជាការចាំបាច់...ត្រូវតែមានការផ្ទុយចំពោះរឿងសព្វសារពើ។» 1 យើងម្នាក់ៗនឹងប្រឈមមុខនឹងពេលពិបាក ហើយសំណួរគឺមិនមែន ពេលណាយើងត្រូវប្រឈមមុខនឹងវានោះទេ ប៉ុន្តែគឺតើយើងត្រូវប្រឈមមុខនឹងវារបៀបណា។

សាវកប៉ុល បានបង្រៀនមេរៀនមួយគួរឱ្យចាប់អារម្មណ៍ តែប៉ុន្មានឆ្នាំប៉ុណ្ណោះពីមុនពេលពួកបរិសុទ្ធនៅរ៉ូមត្រូវប្រឈមមុខជាមួយនឹងការធ្វើទុក្ខបុកម្នេញយ៉ាងឃោរឃៅ ជាងយុគសម័យណាៗទាំងអស់នៃគ្រីស្ទាន។ ប៉ុល បានរំឭកដល់ពួកបរិសុទ្ធថា «គ្រប់ការណ៍ទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ» 2 ព្រះវរបិតាសួគ៌ របស់យើង ដែលស្រឡាញ់យើងពីទ្រង់ពេញលក្ខណៈ និងឥតខ្ចោះ ទ្រង់អនុញ្ញាត

ឱ្យយើង មាន បទពិសោធន៍ដែលនឹង អនុញ្ញាតឱ្យយើងអភិវឌ្ឍន៍រូបកាយ និងឥរិយាបថ ថាយើងត្រូវតែកាន់តែប្រែក្លាយដូចព្រះគ្រីស្ទ។ ការសាកល្បងរបស់យើងកើតមានជាច្រើនទម្រង់ ប៉ុន្តែការសាកល្បងនីមួយៗ អនុញ្ញាឱ្យយើងប្រែក្លាយកាន់តែដូច ព្រះអង្គសង្គ្រោះ នៅ ពេលយើងរៀនស្គាល់សេចក្តីល្អ ដែលកើតមកពីបទពិសោធន៍នីមួយៗ។ យើងយល់អំពីគោលលទ្ធិទាំងនេះ យើងអាចបង្កើននូវភាពប្រាកដយ៉ាងមហិមាចំពោះសេចក្តីស្រឡាញ់របស់ព្រះវរបិតា។ ដែលយើងនឹងមិនដឹងទេ នៅក្នុងជីវិតនេះចំពោះអ្វីដែលយើងប្រឈមមុខ ប៉ុន្តែយើងអាចមានទំនុកចិត្តថា យើងអាចរីកចំរើនពី បទពិសោធន៍ទាំងនោះ។

ឥឡូវនេះខ្ញុំចាប់ផ្តើមដឹងថាវាងាយស្រួលជាង នៅពេលយើងក្រឡេកក្រោយមើលការសាកល្បងទាំងឡាយដែលវាកន្លងផុតទៅ ហើយមើលឃើញនូវអ្វីដែលយើងបានរៀនពីបទពិសោធន៍របស់យើង ប៉ុន្តែឧបសគ្គទាំងនោះ គឺដើម្បីការរីកចំរើន នូវទស្សនៈវិស័យដ៏អស់កល្ប ខណៈពេលដែលយើងឆ្លងកាត់ការប្រឡងរបស់យើង។ ការសាកល្បងរបស់យើងមួយចំនួនហាក់បីដូចជាមិនអស្ចារ្យទេ ប៉ុន្តែចំពោះយើងទាំងអស់គ្នាដែលឆ្លងកាត់បទពិសោធន៍ទាំងនេះ នោះគឺការសាកល្បងពិតជាត្រូវ តម្រូវឱ្យយើងបន្ទាបខ្លួនរបស់យើងចំពោះព្រះភ័ក្ត្រព្រះ និងត្រូវរៀនពីទ្រង់។

នៅក្នុងថ្ងៃអាទិត្យបុណ្យអ៊ីស្ទើរនេះយើងបានចងចាំអំពីជីវិតរបស់ព្រះអង្គសង្គ្រោះរបស់យើង។ ទ្រង់គឺជាអង្គដែល យើងចង់យកគំរូតាម ពីគ្រប់សកម្មភាពទាំងអស់របស់យើង។ ខ្ញុំសូមលើកឡើងប្រាំចំណុចដែលយើងអាចរៀនពីជីវិត នៅនាទីចុងក្រោយរបស់ព្រះអង្គសង្គ្រោះ នៅលើផែនដីដែលអាចជួយយើងប្រឈមមុខនឹងការសាកល្បងរបស់យើង។

ទីមួយ ទ្រង់មិនមែនស្វែងរកធ្វើតាមព្រះទ័យរបស់ទ្រង់ឡើយ ប៉ុន្តែធ្វើតាមព្រះទ័យរបស់ព្រះបិតាទ្រង់វិញ។ ទ្រង់បន្តប្តេជ្ញាបំពេញបេសកកម្មពិសិដ្ឋរបស់ទ្រង់ ទោះបីជាមានការសាកល្បងយ៉ាងណាក្តី។ ដូចជានៅពេលទ្រង់ធ្លាក់ចុះ ត្រូវប្រឈមមុខនៅក្នុងសួនច្បាគែសេម៉ានី ទ្រង់បានទូលសូមថា៖ «ឱ! ព្រះបិតាអើយ បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូលបង្គំទៅ ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះទ័យទ្រង់វិញ»។ 3 នៅពេល ខ្លះយើងឆ្លងកាត់ការឈឺចាប់ និងទុក្ខព្រួយ ដែលនោះប្រហែលជាអាចធ្វើឱ្យយើងរីកចំរើន និងមានការរៀបចំសំរាប់ ការសាកល្បងសក្តានុពលនាពេលអនាគត។ ខ្ញុំសូមសួរសំណួរមួយដល់អ្នកម្តាយទាំងឡាយ «តើអ្នកនឹងធ្វើអ្វីម៉្យាង ដែលបង្កឱ្យមានការឈឺចាប់ និងធ្វើឱ្យកូនរបស់អ្នកយំ នៅពេលដែលពួកគេមិនបានធ្វើអ្វីខុសដែរឬទេ?» ជាការពិតណាស់ អ្នកបានធ្វើ! អ្នកម្តាយល្អគ្រប់រូបបាននាំកូនតូចរបស់អ្នកទៅជួបគ្រូពេទ្យដើម្បីចាក់ថ្នាំវ៉ាក់សាំង ហើយកូនតូចភាគច្រើនចេញពីការិយាល័យរបស់វេជ្ជបណ្ឌិតទាំងទឹកភ្នែក។ ហេតុអ្វីអ្នកធ្វើដូច្នេះ? ពីព្រោះអ្នកដឹងថា ការឈឺចាប់តិចតួចក្នុង ពេលនេះ នឹងជួយការពារពួកគេពីការឈឺចាប់ និងទុក្ខវេទនាដែលអាចកើតមាននាពេលអនាគត។ ព្រះវរបិតាសួគ៌របស់ យើងទ្រង់ជ្រាបតាំងពីដើមដំបូងរហូតដល់ចុងបញ្ចប់។ យើងត្រូវតែធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ និងទុកចិត្តលើទ្រង់។

ទីពីរ ពេលយើងប្រឈមមុខនឹងការសាកល្បង យើងត្រូវរៀនមិនត្អូញត្អែ ឬរអ៊ូរទាំនោះទេ។ នីហ្វៃ នៅក្នុងទស្សននិមិត្ត អំពីការបូជាដ៏ធំដែលធួននឹងបាប លោកបានប្រាប់យើងថា៖ «ហេតុដូច្នេះហើយពួកគេវាយទ្រង់ ក៏ទ្រង់អត់ធ្មត់ ពួកគេទះ ទ្រង់ ក៏ទ្រង់អត់ធ្មត់។ មែនហើយពួកគេស្តោះដាក់ទ្រង់ ក៏ទ្រង់អត់ធ្មត់ ពីព្រោះមកពីសេចក្ដីមេត្តាករុណា និងការអត់ធ្មត់ ដែលទ្រង់មានចំពោះកូនចៅមនុស្ស។» 4 យើងត្រូវតែខំប្រឹងដោះស្រាយបញ្ហាជានិច្ច និងយកឈ្នះលើការសាកល្បង ជំនួសដោយការសួរថា «ហេតុអ្វីជារូបខ្ញុំ?» ឬ «តើខ្ញុំត្រូវធ្វើដូចម្ដេចទើបសមនឹងបានទទួលវា?» សំណួរប្រហែលអាចជា «តើខ្ញុំត្រូវធ្វើអ្វី? តើខ្ញុំអាចរៀនអ្វីខ្លះពីបទពិសោធន៍នេះ? តើខ្ញុំត្រូវមានការផ្លាស់ប្ដូរអ្វីខ្លះ?» ជាច្រើនឆ្នាំកន្លងទៅហើយ អំឡុងពេលធ្វើការបំរើនៅវេនីហ្សូឡា កូនប្រុសពៅរបស់យើងបានចាកចេញពីវិទ្យាល័យដ៏សុខស្រួលរបស់គាត់ ដើម្បីចូលរួមជាមួយយើង។ គាត់មិនបានរអ៊ូរទាំអ្វីទាំងអស់ ប៉ុន្តែតាមជាក់ស្ដែងគាត់ស្មុគ្រស្មាញ នៅពេលដែលគាត់ទៅប្រទេសនេះដែលអ្វីៗគ្រប់យ៉ាងថ្មីសំរាប់គាត់ ប៉ុន្តែវាជាការអភិវឌ្ឍន៍មួយដ៏អស្ចារ្យ បទពិសោធន៍ចេញពីការសាកល្បង មួយនោះ បានប្រែក្លាយទៅជា ពរជ័យមួយដ៏ធំនៅក្នុងជីវិតរបស់គាត់។ គាត់បានបំពេញកិច្ចការទាំងនេះ តាមរយៈការកែប្រែឥរិយាបទ របស់គាត់ និងអភិវឌ្ឍការប្ដេជ្ញាចិត្តដើម្បីជោគជ័យ។

ទីបី ពេលយើងប្រឈមមុខនឹងឧបសគ្គរបស់យើង យើងត្រូវស្វែងរកជំនួយដ៏អស្ចារ្យពីព្រះ។ គឺព្រះអង្គសង្គ្រោះរបស់ យើងទាំងអស់គ្នា ត្រូវស្វែងរកការអធិស្ឋាន «ទទូចរឹតតែខ្លាំងឡើង» 5 ដូចជាទ្រង់នៅក្នុងសួនច្បារគែតសេម៉ានី។ យើងអាចរៀនបង្កើនសេចក្ដីជំនឿដ៏អស្ចារ្យ ប្រសិនបើយើងធ្វើដូច្នេះ។ យើងត្រូវតែចងចាំថា ជាញឹកញាប់ចម្លើយមក ពីព្រះវរបិតាសួគ៌ គឺមិនបានដកយកការសាកល្បងពីយើងទេ ផ្ទុយទៅវិញទ្រង់ជួយពង្រឹងយើង ពេលយើងឆ្លងកាត់ បទពិសោធន៍ទាំងនេះ។ ដូចជាអ្នកដែលដើរតាមអាលម៉ា ព្រះអម្ចាស់អាច «សំរាលបន្ទុកទាំងឡាយដែល ដាក់នៅ លើស្មាអ្នកផង ហើយសូម្បីតែរូបអ្នកក៏នឹងមិនអាចចាប់អារម្មណ៍ថា មានបន្ទុកទាំងនោះនៅលើខ្នងអ្នកឡើយ។» 6 ចំពោះការសាកល្បងទាំងឡាយរបស់យើង យើងគួរតែមិនធ្វើឱ្យជូរចត់ ឬគ្មានការប្ដេជ្ញាចិត្តចំពោះវា ប៉ុន្តែចូរយើងធ្វើ តាមគំរូរបស់ព្រះអង្គសង្គ្រោះគឺទទូចកាន់តែខ្លាំងឡើង កាន់តែស្មោះស្ម័គ្រ និងកាន់តែស្មោះត្រង់។

ទីបួន ត្រូវរៀនបំរើ និងគិតពីអ្នកដទៃទោះជាយើងកំពុងស្ថិតនៅក្នុងគ្រាដែលត្រូវសាកល្បងក្ដី។ ព្រះគ្រីស្ទគឺជាគំរូដ៏មហិមាអំពីការបំរើ។ ជីវិតរបស់ទ្រង់ពោរពេញទៅដោយគំរូនៃការជួយ និងបំរើអ្នកដទៃ ហើយអំណោយទានដ៏អស្ចារ្យ ជាងគេ គឺអ្វីដែលទ្រង់បានធ្វើសំរាប់យើង។ ដូចជាទ្រង់បានមានព្រះបន្ទូលថា៖ «ត្បិតមើលចុះ យើងជាព្រះ បានរងទុក្ខនូវ ការទាំងនេះជំនួសមនុស្សទាំងអស់ ដើម្បីកុំឱ្យគេអាចរងទុក្ខបើសិនជាពួកគេប្រែចិត្ត។» 7 យើងត្រូវតែប្រែចិត្ត បន្ទាប់ មកត្រូវធ្វើតាមគំរូនៃការបំរើរបស់ទ្រង់។ ពេលយើងបំរើអ្នកដទៃ នោះយើងនឹងភ្លេចបញ្ហាផ្ទាល់ខ្លួនរបស់យើង ហើយ តាមរយៈកិច្ចការទាំងនោះ នោះយើងនឹងបានធូស្រាលពីការឈឺចាប់ ឬភាពមិនស្រួលក្នុងចិត្តនៃអ្នកដទៃ យើងពង្រឹងខ្លួន របស់យើង។ នៅក្នុងសន្និសីទចុងក្រោយបង្អស់ ព្យាការីជាទីស្រឡាញ់របស់យើង គឺប្រធាន ថូម៉ាស អេស

ម៉នសុនបានថ្លែងថា៖ ខ្ញុំជឿថាព្រះអង្គសង្គ្រោះកំពុងប្រាប់យើងថាលើកលែងតែយើងត្រូវបោះបង់ខ្លួនឯង នៅក្នុងការបំរើអ្នកដទៃ មិនដូច្នេះទេជីវិតរបស់យើងមានគោលបំណងតិចតួចប៉ុណ្ណោះ។ អស់អ្នកដែល រស់នៅសំរាប់តែខ្លួនឯង នៅទីបំផុតនឹងស្កិត នៅក្នុងភាពងងឹត ហើយត្រូវបាត់បង់និមិត្តរូបនៅក្នុងជីវិត ពួកគេ ខណៈពេលអ្នកដែលបោះបង់ខ្លួនឯង ក្នុងការបំរើ អ្នកដទៃបានរីកចំរើន និងលូតលាស់--- ហើយ ដែលជាសេចក្តីសង្គ្រោះសំរាប់ជីវិតរបស់ពួកគេ។»9

ទីប្រាំ អភ័យទោសឱ្យអ្នកដទៃ ហើយមិនត្រូវស្វែងរកទំលាក់កំហុស ចំពោះស្ថានភាពរបស់យើងលើពួក គេឡើយ។ នៅពេលខ្លះយើងចូលចិត្តនិយាយថា៖ «ប្រសិនបើពួកគេមិនធ្វើដូច្នេះទេ នោះខ្ញុំនឹងគ្មាន ប្រតិកម្មតបវិញដូចខ្ញុំបានធ្វើនោះទេ។» ដែលនេះគឺជានិន្នាការរបស់មនុស្សខាងសាច់ឈាម គឺការទំលាក់ កំហុសទៅលើអ្នកដទៃ ដូច្នេះពួកគេមិនបាច់ទទួល ខុសត្រូវចំពោះសកម្មភាពរបស់ពួកគេផ្ទាល់។ ព្រះអង្គ សង្គ្រោះ បានក្រឡេកមើលអ្នកដំដែកគោលទ្រង់លើឈើឆ្កាង ហើយបានទូលអង្វរដល់ព្រះវរបិតារបស់ ទ្រង់ថា៖ «ឱ! ព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ត្បិតគេមិន ដឹងជាគេធ្វើអ្វីទេ» 10 តើយើងមិនអាចអភ័យទោស ឱ្យបានច្រើនជាងនេះទេឬអី?

នៅពេលដែលយើងឆ្លងកាត់ការសាកល្បងទាំងឡាយនៃជីវិតនេះ ចូរយើងរក្សាសក្តានុពលដ៏អស់កល្ប ជានិច្ច ចូរយើង កុំរអ៊ូ ចូរយើងពោរពេញទៅដោយការអធិស្ឋានបន្ថែមទៀត ចូរយើងបំរើអ្នកដទៃ ចូរយើង អភ័យទោស ដល់គ្នាទៅវិញ ទៅមក។ ពេលយើងធ្វើដូច្នេះ «គ្រប់ការទាំងអស់ [នឹង] ផ្សំគ្នាសំរាប់សេចក្តី ល្អដល់  [យើង] ដែល ស្រឡាញ់ព្រះ»។ 11 ខ្ញុំសូមថ្លែងជាសាក្សីដ៏ឧឡារិក និងជាក់ច្បាស់ថា ព្រះវរបិតា ស្រឡាញ់យើង ហើយទ្រង់បាន បញ្ជូនព្រះរាជបុត្រាទ្រង់មក ដើម្បីបង្ហាញ និងរៀបចំផ្លូវសំរាប់យើង។ ទ្រង់បានរងទុក្ខ បានសុគត ហើយទ្រង់បាន រស់ឡើងវិញ ដើម្បីឱ្យយើងអាចមានជីវិតរស់ ហើយទ្រង់ មានបំណងប្រាថ្នាថាយើង «អាចមានសេចក្តីអំណរ» 12 ទោះជាយើងស្ថិតនៅក្នុងជីវិត សាកល្បងក្តី។ ខ្ញុំសូមពោលពាក្យទាំងនេះ នៅក្នុងព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. នីហ្វៃទី 2  2:11។
2. រ៉ូម 8:28។
3. លូកា 22:42។
4. នីហ្វៃទី 1  19:9។
5. លូកា 22:44។
6. ម៉ូសាយ 24:14។
7. គ. និង ស. 19:16។
8. ថូម៉ាស អេស ម៉នសុន «តើខ្ញុំបានធ្វើអ្វីខ្លះចំពោះនរណាម្នាក់នៅថ្ងៃនេះ?» Ensign ខែ វិច្ឆិកា  2009 ទំព័រ

85។

9. លូកា 23:34។

10. រ៉ូម 8:28។

11. ធីម៉ូថេ 2 2:25។